**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧
## ថ្ងៃអង្គារ ទី២២ ខែសីហា ឆ្នាំ២០២៣

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយស សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា និងជាប្រធានបណ្តោះអាសន្ន ដោយមានវត្តមានតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភាចំនួន **១២៣រូប**។

របៀបវារៈនៃសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៧ នាពេលនេះ គឺ ការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន រដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

ជាកិច្ចចាប់ផ្តើម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានជម្រាបជូនអង្គសភាថា ក្នុងនាមព្រឹទ្ធសមាជិករដ្ឋសភាបានទទួលលិខិតមួយចំនួន ដូចតទៅ៖

- ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៧២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំង ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- លិខិតលេខ ០៣៨/០៨២៣/លគ/គក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីសំណើសុំរៀបចំដំណើរការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញនៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល របស់គណបក្សប្រជាជនកម្ពុជា
- លិខិតលេខ ០៤០/០៨២៣/លគ.គក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ស្តីពីបញ្ជីរាយនាមសមាសភាពប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញ នៃរដ្ឋសភា នីតិកាលទី៧ របស់គណបក្សប្រជាជនកម្ពុជា
- លិខិតចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ស្តីពីបញ្ជីសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភារបស់ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។


វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@nac.org.kh គេហទំព័រ: www.nac.org.kh

យោងច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ អង្គរដ្ឋសភាបានបោះឆ្នោតអនុម័តដោយលើកដៃចំពោះ បញ្ជីរាយនាមសមាសភាពជាកញ្ចប់ ដែលមានប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងផ្តល់សេចក្តីទុកចិត្តដល់សមាសភាពរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដោយទទួលបានសំឡេងយល់ព្រមចំនួន **១២៣សំឡេង** នៃចំនួនសមាជិកទាំងមូល។

**១- សមាសភាពប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់ នៃរដ្ឋសភា មានដូចតទៅ៖**

១- ប្រធានរដ្ឋសភា៖ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី**

២- អនុប្រធានទី១ រដ្ឋសភា៖ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប**

៣- អនុប្រធានទី២ រដ្ឋសភា៖ ឯកឧត្តម **ខេង សួត**

៤- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

-ប្រធាន៖ ឯកឧត្តម **សរ ចំរុង**

-អនុប្រធាន៖ ឯកឧត្តម **សម តារា**

៥- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

-ប្រធាន៖ ឯកឧត្តម **ឈាង វុន**

-អនុប្រធាន៖ ឯកឧត្តម **ឡោក ហ៊ីរ**

៦- គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

-ប្រធាន៖ ឯកឧត្តម **ឡូយ សុផាត**

-អនុប្រធាន៖ ឯកឧត្តម **ម៉ា ឈឿន**

៧- គណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ

-ប្រធាន៖ ឯកឧត្តម **កែប ជុតិមា**

-អនុប្រធាន៖ ឯកឧត្តម **ច័ន្ទ សុផល**

៨- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

-ប្រធាន៖ ឯកឧត្តម **សួស យ៉ារ៉ា**

-អនុប្រធាន៖ ឯកឧត្តម **នឹម ច័ន្ទតារា**

៩- គណៈកម្មការនីតិកម្ម និងយុត្តិធម៌

-ប្រធាន៖ ឯកឧត្តម **អង្គ វង្ស វឌ្ឍនា**

-អនុប្រធាន៖ លោកជំទាវ **គ្រួច សំអាន**



ឥប

១០- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

-ប្រធាន៖ ឯកឧត្តម **ប៉ា សុជាតិវង្ស**

-អនុប្រធាន៖ លោកជំទាវ **ខេង សំវ៉ាដា**

១១- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី

-ប្រធាន៖ លោកជំទាវ **ឡោក ខេង**

-អនុប្រធាន៖ ឯកឧត្តម **សោម ចិន**

១២- គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ប្រធាន៖ លោកជំទាវ **និន សាផុន**

-អនុប្រធាន៖ ឯកឧត្តម **លី ឆេង**

១៣ -គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ

-ប្រធាន៖ ឯកឧត្តម **ប៉ែន ស៊ីម៉ន**

-អនុប្រធាន៖ ឯកឧត្តម **កែវ វីរៈ**

**២- សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា មានដូចតទៅ៖**

I. **នាយករដ្ឋមន្ត្រី**

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត**

II. **ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម **នេត សាវឿន**

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន**

៣- ឯកឧត្តម **ស៊ុន ចាន់ថុល**

៤- ឯកឧត្តម **ហង់ជួន ណារ៉ុន**

៥- ឯកឧត្តម **សាយ សំអាល់**

៦- ឯកឧត្តម **ស សុខា**

៧- ឯកឧត្តម **ទៀ សីហា**

៨- ឯកឧត្តម **កើត រិទ្ធ**

៩- ឯកឧត្តម **សុខ ចិន្តាសោភា**

១០- ឯកឧត្តម **វង្សី វិស្សុត**



ល១

III. **ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តម **គន់ គីម** (ទទួលបន្ទុកបេសកកម្មពិសេស)

២- ឯកឧត្តម **ហូ សិទ្ធី** (ទទួលបន្ទុកបេសកកម្មពិសេស)

៣- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** (ទទួលបន្ទុកបេសកកម្មពិសេស)

៤- ឯកឧត្តម **ឱម យ៉ិនទៀង** (ទទួលបន្ទុកបេសកកម្មពិសេស)

៥- ឯកឧត្តម **អៀង ម៉ូលី** (ទទួលបន្ទុកបេសកកម្មពិសេស)

៦- ឯកឧត្តម **ថោង ខុន** (ទទួលបន្ទុកបេសកកម្មពិសេស)

៧- ឯកឧត្តម **ពេជ សោភ័ន** (ទទួលបន្ទុកបេសកកម្មពិសេស)

៨- ឯកឧត្តម **ព្រុំ សុខា** (ទទួលបន្ទុកបេសកកម្មពិសេស)

៩- ឯកឧត្តម **សក់ សេដ្ឋា** (ទទួលបន្ទុកបេសកកម្មពិសេស)

១០- ឯកឧត្តម **អូស្មាន ហាស្សាន់** (ទទួលបន្ទុកបេសកកម្មពិសេស)

១១- ឯកឧត្តម **អ៊ី ឈាន** (ទទួលបន្ទុកបេសកកម្មពិសេស)

១២- ឯកឧត្តម **អ៊ុក ប្រាថ្នា** (ទទួលបន្ទុកបេសកកម្មពិសេស)

១៣- ឯកឧត្តម **អ៊ុច បូររិទ្ធ** (ទទួលបន្ទុកបេសកកម្មពិសេស)

១៤- ឯកឧត្តម **ស្វាយ ស៊ីថា** (ទទួលបន្ទុកបេសកកម្មពិសេស)

១៥- ឯកឧត្តម **ឆៃ ស៊ីណារិទ្ធ** (ទទួលបន្ទុកបេសកកម្មពិសេស)

១៦- ឯកឧត្តម **លី ធុជ** (ទទួលបន្ទុកបេសកកម្មពិសេស)

១៧- ឯកឧត្តម **ឆែម គាតរិទ្ធី** (ទទួលបន្ទុកបេសកកម្មពិសេស)

១៨- ឯកឧត្តម **ឈៀង យ៉ាណារ៉ា** (ទទួលបន្ទុកបេសកកម្មពិសេស)

១៩- ឯកឧត្តម **សុក ស៊ីផាន់ណា** (ទទួលបន្ទុកបេសកកម្មពិសេស)

២០- ឯកឧត្តម **កែវ រ៉េមី** (ទទួលបន្ទុកបេសកកម្មពិសេស)

២១- ឯកឧត្តម **គី តិច** (ទទួលបន្ទុកបេសកកម្មពិសេស)

IV. **រដ្ឋមន្ត្រី**

១- ឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

២- ឯកឧត្តម **ស សុខា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣- ឯកឧត្តម **ទៀ សីហា** រដ្ឋមន្ត្រីក្រសួងការពារជាតិ

៤- ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦- ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៧- ឯកឧត្តម **ឆាយ ឫទ្ធិសែន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

៨- លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៩- ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០- ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

១១- ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ

១២- ឯកឧត្តម **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

១៣- ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៤- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៥- ឯកឧត្តម **អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន

១៦- ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

១៧- ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន

១៨- ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១៩- ឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច

២០- ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២១- ឯកឧត្តម **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល

២២- ឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

២៣- លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

២៤- ឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍

២៥- ឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

២៦- លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

២៧- ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២៨- ឯកឧត្តម **ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

២៩- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

៣០- ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។



ឧ២ ម

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា បានប្រកាសថា សមាសភាព ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំង នាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់ នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ នីតិកាលទី៧ នៃរដ្ឋសភា ត្រូវបានអង្គសភាបោះឆ្នោតជាប់ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នា សម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៧។

នៅក្នុងឱកាសនៃការទទួលតំណែងជាប្រធានរដ្ឋសភា នីតិកាលទី៧ នោះដែរ លោកជំទាវ កិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធានរដ្ឋសភា បានថ្លែងអំណរព្រះគុណ និងអំណរគុណដ៏ ជ្រាលជ្រៅបំផុតចំពោះ **សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ** សមាជិក សមាជិកា រដ្ឋសភាទាំងអស់ ដែលបានបោះឆ្នោតសម្តែងការទុកចិត្តគាំទ្រផ្តល់មហាកិត្តិយសដ៏ខ្ពង់ខ្ពស់ចំពោះ **លោកជំទាវផ្ទាល់** ជាប្រធានរដ្ឋសភា ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា និងឯកឧត្តម **វង សូត** អនុប្រធានទី២ រដ្ឋសភា ឱ្យទទួលភារកិច្ចជាថ្នាក់ដឹកនាំរដ្ឋសភា នីតិកាលទី៧ នេះ ។

**លោកជំទាវ** ក៏បានសូមព្រះបរមរាជានុញ្ញាតថ្លែងនូវអំណរព្រះមហាករុណាធិគុណ និង កតញ្ញុតាធម៌ ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ដែលព្រះអង្គទ្រង់បានសព្វព្រះរាជ ហឫទ័យ ស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត និងប្រោសប្រទានព្រះរាជសុន្ទរកថា បើកសម័យប្រជុំដំបូង នៃរដ្ឋសភា នីតិកាលទី៧ នាព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ។

**លោកជំទាវប្រធានរដ្ឋសភា** ក៏បានសម្តែងការកោតសរសើរ និងសូមថ្លែងអំណរគុណ ជាអនេកចំពោះជនរួមជាតិទូទាំងប្រទេស ដែលបានបំពេញកាតព្វកិច្ចដ៏ថ្លៃថ្លាបំផុត ដោយបាន អញ្ជើញទៅបោះឆ្នោតគាំទ្រគណបក្សនយោបាយនានាដែលខ្លួនពេញចិត្ត ក្នុងបរិយាកាសថ្លៃថ្នូរ គ្មានអំពើហិង្សា ធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ស្រប តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

**លោកជំទាវកិត្តិសង្គហបណ្ឌិត** បានមានប្រសាសន៍ថ្លែងអំណរគុណផងដែរ ចំពោះ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលបានចូលរួមសង្កេតការណ៍អំពី ដំណើរការនៃការបោះឆ្នោត និងបណ្តាប្រទេសជាមិត្ត ដែលបានគាំទ្រលទ្ធផលនៃការបោះឆោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដោយបានធ្វើការវាយតម្លៃថាដំណើរការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយសុវត្ថិភាព ឯករាជ្យ មិនលម្អៀង មានវិជ្ជាជីវៈ តម្លាភាព សន្តិភាព សេរី និងយុត្តិធម៌ ។



៦

ក្នុងនាមរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ នេះ ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រមទាំងច្បាប់ និងបទដ្ឋានគតិយុត្តនានាជាធរមាន លោកជំទាវ បានប្រកាសជាឱឡារិកនាពេលនេះថា រដ្ឋសភានឹងខិតខំបំពេញនូវបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងភាពជាតំណាងរបស់ប្រជាពលរដ្ឋខ្មែរ ដោយសហការឱ្យបានល្អជាមួយគ្រប់ស្ថាប័នជាតិ ជាអាទិ៍ ស្ថាប័ននីតិប្រតិបត្តិ ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ ប្រជាជាតិ និងមាតុភូមិកម្ពុជា ជានិច្ចនិរន្តរ៍តរៀងទៅ ។

បន្ទាប់មក លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធានរដ្ឋសភា បានអញ្ជើញ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាមានមតិជូនអង្គសភា។

សម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ បានប្រកាសផ្អាកសម័យប្រជុំ នៅវេលាម៉ោង ៩:២៥នាទី ថ្ងៃខែឆ្នាំដដែល។ សម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ បន្តទៀតនឹងមានជូនដំណឹងនៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប។ ៚

ថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**